ភាសាខ្មែរ

# សម្រាប់ជនបរទេសដែលត្រូវបានបញ្ជីជានិវេសនជននៅប្រទេសជប៉ុន

អ្នកនឹងទទួលបានការជូនដំណឹងពីលេខសន្តិសុខសង្គម និងសារពើពន្ធ ចំនួន12 ខ្ទង់របស់អ្នក (ឬហៅថាលេខឯកត្តជន ឬ "លេខរបស់ខ្ញុំ") ចាប់ពីខែតុលា ឆ្នាំ 2015 តទៅ។

## 1. តើលេខឯកត្តជន (ហៅក្រៅថា "លេខរបស់ខ្ញុំ") គឺជាអ្វី?

លេខឯកត្តជនត្រូវបានចេញក្រោមប្រព័ន្ធលេខសន្តិសុខសង្គម និងសារពើពន្ធ ដែលជាមូលដ្ឋានសម្រាប់ភ្ជាប់ និងប្រមូលផ្តុំព័ត៌មានផ្ទាល់ខ្លួន ដែលត្រូវបានចែកចាយនៅតាមទីភ្នាក់ងារជាច្រើន ក្រោមឈ្មោះរបស់បុគ្គលដែលជាម្ចាស់របស់វា។ ប្រព័ន្ធនេះដើរតួជាហេដ្ឋារចនាសម្ព័ន្ធសង្គម ដើម្បីបង្កើនប្រសិទ្ធភាព និងតម្លាភាពនៃប្រព័ន្ធសន្តិសុខសង្គម និងសារពើពន្ធ ផ្តល់ភាពងាយស្រួលបន្ថែមទៀតដល់សាធារណជន នឹងបង្កើតសង្គមដ៏ត្រឹមត្រូវ នឹងយុត្តិធម៌មួយ។
ជនបរទេសដែលត្រូវបានចុះបញ្ជីជានិវេសនជននៅប្រទេសជប៉ុន (និវេសនជនរយៈពេលមធ្យម និវេសនជនអចិន្ត្រៃយ៍ពិសេស។ល។) ក៏នឹងទទួលបានលេខឯកត្តជនរបស់ពួកគេផងដែរ។

## 2. ពេលណាដែលត្រូវប្រើលេខឯកត្តជន

- ◆ អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅនិយោជករបស់អ្នក សម្រាប់ប្រើក្នុងការបង្កើតវិញ្ញាបនបត្រ/លិខិតបញ្ជាក់ប្រាក់ចំណូល និងពន្ធកាត់ទុក ដែលត្រូវការសម្រាប់នីតិវិធីសារពើពន្ធ និងសន្តិសុខសង្គម។
- ◆ អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅក្រុមហ៊ុនសន្តិសុខ និងក្រុមហ៊ុនធានារ៉ាប់រង សម្រាប់ជាកំណត់សម្គាល់លើឯកសារគតិយុត្តិនានា ដែលត្រូវបានប្រើប្រាស់សម្រាប់នីតិវិធីសារពើពន្ធ។
- ◆ អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅកាន់ការិយាល័យសោធន ដើម្បីទាមទារអត្ថប្រយោជន៍សោធននិយោជិតរបស់អ្នក។
- ◆ អ្នកនឹងបង្ហាញលេខឯកត្តជនរបស់អ្នកទៅការិយាល័យក្រុងរបស់អ្នក ដើម្បីទទួលបានអត្ថប្រយោជន៍សុខុមាលភាព។

## 3. នីតិវិធីចាំបាច់

- ◆ ការិយាល័យក្រុងនឹងផ្ញើប័ណ្ណជូនដំណឹងមួយទៅកាន់អាសយដ្ឋានចុះបញ្ជីរបស់អ្នក។
  អ្នកអាចនឹងមិនបានទទួលប័ណ្ណជូនដំណឹង ប្រសិនបើអាសយដ្ឋានបច្ចុប្បន្នរបស់អ្នកមិនត្រូវបានចុះបញ្ជីទេ។ សូមបញ្ជាក់អាសយដ្ឋានចុះបញ្ជីរបស់អ្នកជាមុន។
- ◆ ចាប់ផ្តើមពីខែតុលា ឆ្នាំ 2015 តទៅ គ្រប់ក្រុមគ្រួសារទាំងអស់នឹងទទួលបានស្រោមសំបុត្រមួយ (ផ្ញើតាមប្រៃសណីយ៍ដោយត្រូវមានហត្ថលេខាបញ្ជាក់ពីអ្នកទទួល) ដែលក្នុងនោះមានប័ណ្ណជូនដំណឹង ដែលបង្ហាញពីលេខឯកត្តជនរបស់សមាជិកគ្រួសារទាំងអស់។ ប័ណ្ណនេះមានសារៈសំខាន់ ពីព្រោះវាបញ្ជាក់ពីលេខឯកត្តជនរបស់អ្នកក្នុងនីតិវិធីសារពើពន្ធ និងសន្តិសុខសង្គម។
  សូមប្រុងប្រយ័ត្នជៀសវៀងការច្រលំបោះចោលប័ណ្ណនេះ។
- ◆ អ្នកអាចស្នើសុំប័ណ្ណសម្គាល់លេខឯកត្តជនមួយបាន។
  មានជម្រើសដាក់ពាក្យជាច្រើនសម្រាប់ឲ្យអ្នកជ្រើសរើស ដូចជាផ្ញើត្រលប់ទៅវិញតាមប្រៃសណីយ៍នូវពាក្យសុំប័ណ្ណសម្គាល់លេខឯកត្តជនដោយមានភ្ជាប់ជាមួយនូវរូបថតចំពីមុខរបស់អ្នក ឬដាក់ពាក្យស្នើសុំតាមប្រព័ន្ធអ៊ិនធឺណេត ដោយមានភ្ជាប់រូបថតចំពីមុខរបស់អ្នកដែលថតដោយទូរស័ព្ទប្រភេទ smartphone។ នីតិវិធីដាក់ពាក្យស្នើសុំលម្អិតនឹងត្រូវបានពណ៌នានៅក្នុងឯកសារណែនាំនៅក្នុងស្រោមសំបុត្រដែលត្រូវបានបញ្ជូនទៅ នៅឬបន្ទាប់ពីខែ តុលា ឆ្នាំ 2015។
- ◆ បន្ទាប់មកអ្នកនឹងទទួលបានលេខឯកត្តជនរបស់អ្នក។
  នៅខែមករា ឬ ខែក្រោយមកទៀតនៅឆ្នាំ 2016 អ្នកនឹងទទួលបានការជូនដំណឹងថា ប័ណ្ណសម្គាល់លេខឯកត្តជនរបស់អ្នក គឺរួចរាល់សម្រាប់ចេញជូន។ ប្រសិនបើអ្នកជ្រើសរើសទទួលប័ណ្ណនេះនៅការិយាល័យក្រុង សូមយកឯកសារបីដូចខាងក្រោមទៅជាមួយ។ ការចេញប័ណ្ណលើកទីមួយ គឺមិនគិតប្រាក់នោះទេ។
  - ✓ ប័ណ្ណជូនដំណឹង
  - ✓ ការជូនដំណឹងពីការចេញប័ណ្ណសម្គាល់ (បានទទួលបន្ទាប់ពីដាក់ពាក្យសុំ)
  - ✓ ប័ណ្ណសម្គាល់ខ្លួន (ដូចជាប័ណ្ណបើកបរ លិខិតឆ្លងដែន ប័ណ្ណស្នាក់នៅជាដើម)

## 4. តើប័ណ្ណសម្គាល់លេខឯកត្តជនគឺជាអ្វី?

- ប័ណ្ណនេះបញ្ជាក់ទាំងលេខឯកត្តជនរបស់អ្នក និងអត្តសញ្ញាណរបស់អ្នកតាមនីតិវិធីណាមួយដែលទាក់ទងនឹងលេខឯកត្តជន។ វាក៏អាចប្រើជាអត្តសញ្ញាណប័ណ្ណផ្លូវការរបស់អ្នកផងដែរ។
- អ្នកអាចបន្ថែមវិញ្ញាបនបត្រអេឡិចត្រូនិចមួយទៅនឹងប័ណ្ណសម្គាល់នេះដោយឥតគិតថ្លៃ ហើយប្រើប្រាស់វាសម្រាប់ប្រតិវេទនពន្ធតាមប្រព័ន្ធអ៊ិនធឺណេត។
- អ្នកក៏អាចប្រើប័ណ្ណសម្គាល់នេះដើម្បីទទួលបានសេវាផ្សេងៗដែលផ្តល់ដោយរដ្ឋាភិបាល/អាជ្ញាធរមូលដ្ឋានរបស់អ្នក ដូចមានចែងបញ្ជាក់នៅក្នុងបទប្បញ្ញត្តិមូលដ្ឋាននោះ (ឧទា. សេវាបណ្ណាល័យសាធារណៈ ការចេញវិញ្ញាបនបត្រចុះបញ្ជីត្រា)។ ក្រុងមួយចំនួនថែមទាំងអនុញ្ញាតឲ្យហាងលក់ទំនិញចេញវិញ្ញាបនបត្រសាធារណៈនានាទៀតផង។
- ប័ណ្ណចុះបញ្ជីនិវេសនជនមូលដ្ឋានរបស់អ្នក នឹងមានសុពលភាពរហូតដល់កាលបរិច្ឆេទផុតកំណត់។ ប៉ុន្តែអ្នកចាំបាច់ត្រូវប្រគល់ប័ណ្ណនេះមកវិញ នៅពេលដែលអ្នកទទួលបានប័ណ្ណសម្គាល់លេខឯកត្តជន។
- បន្ទះឈីប (IC chip) នៅលើប័ណ្ណសម្គាល់លេខឯកត្តជន នឹងមានផ្ទុកឈ្មោះ អាសយដ្ឋាន ថ្ងៃខែឆ្នាំកំណើត ភេទ លេខឯកត្តជន និងព័ត៌មានផ្សេងទៀត ដែលមានសរសេរនៅផ្នែកខាងមុខនៃប័ណ្ណ ព្រមទាំងវិញ្ញាបនបត្រអេឡិចត្រូនិចផងដែរ បើមាន។ នឹងមិនមានការកត់ត្រាព័ត៌មានសម្ងាត់ផ្ទាល់ខ្លួន ដូចជាប្រាក់ចំណូលរបស់អ្នកនោះទេ។

## 5. បម្រុងប្រយ័ត្នក្នុងការទុកដាក់លេខឯកត្តជន

- មិនមានបុគ្គលណាម្នាក់ត្រូវបានអនុញ្ញាតឲ្យប្រើប្រាស់ ឬ ប្រមូលប័ណ្ណសម្គាល់លេខឯកត្តជនឡើយ លើកលែងតែច្បាប់អនុញ្ញាត។ សូមកុំធ្វេសប្រហែសបង្ហាញលេខឯកត្តជនរបស់អ្នកឲ្យអ្នកដទៃបានឃើញ។
- បុគ្គលណាម្នាក់ដែលទទួលលេខឯកត្តជនរបស់អ្នកដទៃដោយមិនស្របច្បាប់ និងបុគ្គលទទួលសិទ្ធិអនុញ្ញាតណាម្នាក់ដែលប្រើប្រាស់លេខឯកត្តជនរបស់អ្នកដទៃ ដែលផ្តល់ដល់ភាគីទីបី នូវឯកសារដែលមានផ្ទុកលេខឯកត្តជន និងព័ត៌មានសម្ងាត់ផ្ទាល់ខ្លួនផ្សេងទៀតដោយវិធីមិនស្របច្បាប់ នឹងត្រូវទទួលការផ្តន្ទាទោស។

## 6. ព័ត៌មានទំនាក់ទំនង

- ហៅទូរស័ព្ទទៅកាន់ផ្នែកសេវាព័ត៌មាន
  **0570-20-0178 (ភាសាជប៉ុន)**
  **0570-20-0291 (ភាសាអង់គ្លេស ចិន កូរ៉េ អេស្ប៉ាញ និងព័រទុយហ្គាល់)**
  [រហូតដល់ថ្ងៃទី 30 ខែកញ្ញា ឆ្នាំ 2015]
  ម៉ោង 9:30-17:30 រៀងរាល់ថ្ងៃធ្វើការ (បិទនៅចុងសប្តាហ៍ ថ្ងៃឈប់សម្រាកក្នុងឱកាសបុណ្យជាតិ និងថ្ងៃឈប់សម្រាកចុងឆ្នាំ/ចូលឆ្នាំថ្មី)
  [ចាប់ពីថ្ងៃទី 1 ខែតុលា 2015 ដល់ ថ្ងៃទី 31 ខែមិនា ឆ្នាំ 2016]
  ម៉ោង 9:30-20:00 រៀងរាល់ថ្ងៃធ្វើការ, 9:30-17:30 ថ្ងៃចុងសប្តាហ៍ និងថ្ងៃឈប់សម្រាក

សម្គាល់៖ នឹងមានការគិតថ្លៃសេវាទូរស័ព្ទ ពីព្រោះវាគឺជាសេវា Navi-Dial។

